សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីស្រូវ អញ្ចឹងជាទូទៅស្រូវគឺយើងដាំដុះនៅក្នុងខែវស្សា និងនៅក្នុងរដូវប្រាំង ដែលរដូវវស្សា គេហៅថាស្រូវវស្សា រីឯនៅពេលដែលគេដាំដុះនៅក្នុងរដូវប្រាំង គឺយើងហៅថាស្រូវប្រាំង អញ្ចឹងដោយសារតែប្រជាជនកម្ពុជាគឺ 90 ភាគរយគឺជាកសិករ អញ្ចឹងគាត់មានប្រកបមុខរបរដាំស្រូវ ឬក៏ធ្វើស្រូវ។

អញ្ចឹងយើងមកមើលនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ គឺកសិករម្នាក់ គាត់កំពុងតែភ្ជួរស្រែ អញ្ចឹងនៅក្នុងរូបភាពទី ១ នេះ យើងឃើញគាត់ភ្ជួរស្រែដោយប្រើសត្វក្របី អញ្ចឹងសត្វក្របីគឺមានពណ៌ខ្មៅ សត្វក្របីមានពណ៌ខ្មៅ ហើយមានជើង ៤ និងមានកន្ទុយមួយផងដែរ កន្ទុយគឺនៅខាងក្រោយ ហើយវាមានស្នែង ២ ស្រួចៗ អញ្ចឹងស្នែងរបស់សត្វក្របីគឺនៅលើក្បាល ហើយស្នែងរបស់សត្វក្របីគឺកោងនិងស្រួច អញ្ចឹងមានកសិករម្នាក់ គាត់កំពុងតែភ្ជួរស្រែ ដោយគាត់ពាក់អាវសដៃវែង ហើយស្លៀកខោពណ៌ផ្កាឈូកជើងវែង គាត់មានពាក់មួកស្លឹកត្នោតផងដែរ អញ្ចឹងដោយសារតែការធ្វើស្រែ គេធ្វើនៅពេលព្រឹក ព្រោះថាប្រសិនបើធ្វើនៅពេលថ្ងៃគឺវាក្តៅ គឺពិបាកធ្វើការ ដូច្នេះគឺគេភ្ជួរស្រែ ឬក៏រាស់ស្រែនៅពេលព្រឹក អញ្ចឹងគាត់ពាក់អាវដៃវែង ខោជើងវែង និងមានពាក់មួក ដើម្បីការពារកម្តៅផងដែរ ព្រោះថានៅពេលដែលធ្វើស្រែគឺក្តៅ ដូច្នេះហើយ គាត់ត្រូវការពារកម្តៅផងដែរ អញ្ចឹងនៅក្នុងរូបភាពនេះ គឺយើងឃើញសត្វក្របីកំពុងតែដើរអូសនង្គ័ល ឬអូសរនាស់ អញ្ចឹងឧបករណ៍សម្រាប់ភ្ជួរស្រែ យើងហៅថានង្គ័ល ហើយឧបករណ៍សម្រាប់ធ្វើឲ្យដីរាប ងាយស្រួលធ្វើស្រែ យើងហៅថារនាស់ អញ្ចឹងសត្វក្របីកំពុងតែដើរអូសរនាស់ ដោយមានកសិករឈរពីក្រោយ ឬក៏ដើរតាមក្រោយ ដើម្បីបញ្ជា អញ្ចឹងគេធ្វើស្រែនៅក្នុងដីល្បាប់ ដោយសារតែមានភ្លៀង ឬក៏មានទឹកនៅក្នុងស្រែ ទើបគេអាចភ្ជួររាស់បាន ដូច្នេះគឺគេធ្វើស្រែនៅក្នុងដីល្បាប់ ដោយយើងឃើញនៅខាងក្រោយ គឺមានដើមឈើពណ៌បៃតង ដូចជាដើមត្នោត និងដើមស្មៅផងដែរ អញ្ចឹងវាលស្រែគឺអត់សូវមានដើមឈើច្រើនប៉ុន្មានទេ គឺវាលស្រែសម្បូរតែដើមត្នោត អញ្ចឹងនៅខាងលើ យើងឃើញមានពពកកំពុងតែហោះផងដែរ អញ្ចឹងបានន័យថាមេឃស្រឡះ អញ្ចឹងគឺមេឃអត់ភ្លៀងនោះទេ បានន័យថាអាចភ្លៀងពីយប់ផងដែរ អញ្ចឹងពេលព្រឹកឡើង គឺមេឃអត់ភ្លៀង គឺងាយស្រួលក្នុងការភ្ជួរស្រែ អញ្ចឹងរូបភាពទី ១ គឺកសិករ គាត់កំពុងតែភ្ជួរស្រែ ដោយប្រើសត្វក្របី។

ចូលមកដល់រូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញកសិករដដែលនោះ គាត់បានភ្ជួរស្រែ ដោយប្រើម៉ាស៊ីនភ្ជួរស្រែវិញម្តង អញ្ចឹង ពីដើម ឬក៏ពីមុន គឺយើងប្រើប្រាស់កម្លាំងសត្វ ដើម្បីអូសទាញនៅក្នុងការភ្ជួរស្រែ ឬក៏នៅក្នុងការរាស់ស្រែ ក៏ប៉ុន្តែឥឡូវ ដើម្បីចំណេញពេល

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺកសិករ គាត់ប្រើម៉ាស៊ីនវិញម្តង ដាក់ស្តែងដូចនៅក្នុងរូបភាពទី ២ នេះ គឺយើងឃើញកសិករម្នាក់ ដែលគាត់ពាក់អាវពណ៌ស ខោជើងវែងពណ៌ផ្កាឈូក និងមានពាក់មួកស្លឹកត្នោតផងដែរនោះ គឺគាត់កំពុងតែកាន់ចង្កូតម៉ាស៊ីន ដើម្បីបញ្ជាម៉ាស៊ីនក្នុងការភ្ជួរស្រែ អញ្ចឹងការភ្ជួរស្រែដោយប្រើម៉ាស៊ីន គឺមានលក្ខណៈលឿន ហើយរហ័សនិងងាយស្រួល ដោយសារតែមិនប្រើប្រាស់កម្លាំងអូសទាញនៃសត្វនោះទេ អញ្ចឹងវាលឿន ហើយងាយស្រួលក្នុងការធ្វើស្រែ អញ្ចឹងគឺចំណេញពេលវេលាដល់កសិករ ដូច្នេះនៅក្នុងសម័យឥឡូវ ឬក៏បច្ចុប្បន្ន គឺកសិករ គាត់ភាគច្រើន គឺគាត់ចូលចិត្តប្រើប្រាស់ម៉ាស៊ីន ជាជាងការប្រើប្រាស់កម្លាំងសត្វក្របី អញ្ចឹងនៅក្នុងរូបភាពទី ២ គឺកសិករ គាត់កំពុងតែភ្ជួរស្រែ ដោយប្រើប្រាស់ម៉ាស៊ីន។

ចូលមកដល់រូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញកសិករ គាត់កំពុងតែចាក់គ្រាប់ពូជ ត្រាំទៅក្នុងទឹក អញ្ចឹងនៅក្នុងរូបភាពទី ៣ នេះ យើងឃើញមានចានដែកធំមួយ អញ្ចឹងចានដែកធំមួយ ពណ៌រៀងប្រផេះ ហើយមានទឹកនៅក្នុងនោះផងដែរ អញ្ចឹងកសិករ គាត់កំពុងតែចាក់គ្រាប់ស្រូវចេញពីក្នុងថង់មួយ ឬកញ្ចប់មួយ ចាក់ចេញពីក្នុងថង់ ឬក៏ក្នុងកញ្ចប់ ដែលមានពណ៌ផ្កាឈូក ហើយគាត់ចាក់គ្រាប់ស្រូវ ឬក៏គ្រាប់ពូជនោះ ចូលទៅក្នុងចានដែក អញ្ចឹងគ្រាប់ស្រូវដែលប្រើសម្រាប់ដាំដុះនៅក្នុងការធ្វើស្រែ គឺយើងហៅថាគ្រាប់ពូជ អញ្ចឹង កសិករ គាត់ចាក់ចូលទៅក្នុងចានដែក ដើម្បីត្រាំគ្រាប់ពូជ ជាទូទៅគ្រាប់ពូជ គឺយើងត្រូវត្រាំពីមួយថ្ងៃទៅពីរថ្ងៃ ដើម្បីឲ្យគ្រាប់ពូជនោះដុះបានល្អ អញ្ចឹងមុននឹងយកទៅធ្វើស្រែ គឺគេត្រូវត្រាំគ្រាប់ពូជនៅក្នុងទឹកជាមុនសិន ដូច្នេះនៅក្នុងរូបភាពទី ៣ នេះ គឺកសិករ គាត់កំពុងតែចាក់គ្រាប់ពូជត្រាំនៅក្នុងទឹក មុននឹងគាត់យកទៅធ្វើស្រែ។

បន្ទាប់មកទៀតចូលដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញកសិករ គាត់កំពុងតែដើរបាចស្រូវចូលទៅក្នុងស្រែ អញ្ចឹងអម្បាញ់មិញ ដោយសារតែគាត់ត្រាំគ្រាប់ពូជរួចហើយ ហើយស្រែរបស់គាត់បានភ្ជួររាស់រួចហើយ អញ្ចឹងគឺវា គឺជាពេលសម្រាប់ធ្វើការសាបព្រួសគ្រាប់ពូជស្រូវរបស់គាត់ អញ្ចឹងនៅក្នុងរូបភាពទី ៣ នេះ យើងឃើញកសិករម្នាក់ដដែល ដែលគាត់ពាក់អាវដៃវែង ខោជើងវែង និងមានពាក់មួក គាត់កំពុងតែកាន់កន្ត្រកមួយ អញ្ចឹងកន្ត្រករបស់គាត់ពណ៌ផ្កាឈូក ហើយមានដៃយួរផងដែរ ដោយគាត់ស៊កកន្ត្រកនោះចូលទៅក្នុងដៃស្តាំរបស់គាត់ រីឯដៃឆ្វេងគាត់ចាប់គ្រាប់ពូជចេញពីកន្ត្រក បាចចូលទៅក្នុងស្រែ អញ្ចឹងការធ្វើរបៀបនេះ គេហៅថាការសាបស្រូវ ឬក៏ការព្រួសស្រូវ អញ្ចឹងគាត់ដើរនៅក្នុងស្រែដែលភ្ជួររាស់រួចហើយនោះ ដែលយើងឃើញនៅក្នុងស្រែរបស់គាត់ គឺមានទឹកដក់តិចៗ អញ្ចឹងទឹកដក់តិចៗនេះ គឺធ្វើឲ្យដីរបស់គាត់គឺមានសំណើម

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងធ្វើការដាំដុះបានល្អ ដូច្នេះគាត់ក៏កាន់គ្រាប់ពូជស្រូវដែលគាត់បានត្រាំរួច
បាចទៅក្នុងស្រែរបស់គាត់ ម្តងមួយក្តាប់ៗ អញ្ចឹងគាត់ក្តាប់គ្រាប់ស្រូវចេញពីក្នុងកន្ត្រកគ្រាប់ពូជ
ហើយគាត់បាចចូលទៅក្នុងស្រែ ដែលយើងហៅថាការសាបស្រូវ ឬក៏ការព្រួសស្រូវ
អញ្ចឹងយើងឃើញនៅថ្ងៃនេះ គឺមានមេឃស្រឡះល្អ អញ្ចឹងគាត់ធ្វើស្រែនៅក្រោមមេឃស្រឡះ
ដែលជាទូទៅយើងធ្វើស្រែនៅពេលព្រឹក រីឯជើងគាត់ យើងឃើញគាត់ដើរនៅក្នុងល្បាប់
ឬក៏ដើរនៅក្នុងភក់ ដែលល្បាប់ឬក៏ភក់នេះ គឺជាដីស្រែរបស់គាត់ ដែលគាត់បានភ្ជួររាស់រួចរាល់ហើយ
អញ្ចឹងដីស្រែដែលភ្ជួររាស់រួចរាល់ គឺជាពេលសម្រាប់តែធ្វើការសាបស្រូវ ឬក៏ព្រួសស្រូវដើម្បីដាំដុះ។

ចូលមកដល់រូបភាពទី ៥ នៅក្នុងរូបភាពទី ៥ យើងឃើញជាសំណាបមួយគុម្ពធំ អញ្ចឹង
ក្រោយពេលដែលយើងសាប ឬក៏យើងព្រួសគ្រាប់ស្រូវចូលទៅក្នុងស្រែរួចរាល់ហើយ
រយៈពេលមួយសប្តាហ៍ ឬក៏ ២ សប្តាហ៍ក្រោយមក គ្រាប់ស្រូវនោះនឹងដុះទៅជាដើមស្រូវ
អញ្ចឹងដើមស្រូវ នៅពេលដែលវានៅខ្ចី [យើងហៅថា] ដើមស្រូវខ្ចី គឺយើងហៅថាសំណាប
អញ្ចឹងសំណាប នៅពេលដែលវាដុះបានបន្តិច ប្រហែលជាលូតវែងបន្តិចក្រោយមក
គឺកសិករនឹងចាប់ផ្តើមដកសំណាបនោះយកមកចងជាបាច់ៗ
ដែលជាក់ស្តែងយើងឃើញនៅក្នុងរូបភាពទី ៥ នេះ គឺកសិករដកដើមស្រូវតូចៗ
ឬក៏យើងហៅថាសំណាបនោះរួចរាល់ហើយ ហើយគាត់ក៏ចងជាបាច់ៗ ដើម្បីយកទៅស្ទូង
អញ្ចឹងគាត់ចងជាបាច់ៗ ប៉ុន្តែគាត់អត់យកទៅណាឆ្ងាយចេញពីស្រែរបស់គាត់ទេ គឺគាត់ចងហើយ
គាត់ដាក់នៅក្នុងស្រែរបស់គាត់ដដែល ដើម្បីរង់ចាំរយៈពេលស្ទូង
អញ្ចឹងដើម្បីកុំឲ្យសំណាបរបស់គាត់រាយប៉ាយ ឬក៏រាយប៉ាយនៅក្នុងស្រែរបស់គាត់
គាត់ត្រូវចងសំណាបនោះជាបាច់ៗ ដើម្បីឲ្យមានសណ្តាប់ធ្នាប់និងរបៀបរៀបរយ
មុននឹងយកទៅធ្វើការស្ទូងស្រូវ។

ចូលមកដល់រូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា បន្ទាប់ពីគាត់ដកសំណាបរបស់គាត់
ចេញពីក្នុងស្រែរួចរាល់ហើយ អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ៦ នេះ
គឺកសិករកំពុងតែយកដើមស្រូវ ឬក៏ដើមសំណាបនោះទៅដោតចូលនៅក្នុងស្រែវិញ
អញ្ចឹងការដោតដើមស្រូវ ឬក៏ដោតសំណាបចូលទៅក្នុងស្រែ យើងហៅថាការស្ទូង
អញ្ចឹងយើងឃើញកសិករ គាត់កំពុងតែដើរនៅក្នុងទឹក បានន័យថាស្រែរបស់គាត់គឺមានទឹក
អញ្ចឹងជាទូទៅការស្ទូងស្រូវ គឺយើងត្រូវការទឹកនៅក្នុងស្រែច្រើនជាងការសាប ឬក៏ការភ្ជួររាស់បន្តិច
ដោយសារតែសន្ទូងយើងត្រូវការទឹក អញ្ចឹងដើមស្រូវដែលយើងយកទៅដោតចូលក្នុងដី
យើងហៅថាសន្ទូង ហើយសកម្មភាពដែលយើងយកដើមស្រូវដោតចូលក្នុងដី យើងហៅថា
ការស្ទូងស្រូវ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញកសិករ គាត់កំពុងតែត្រកង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏គាត់កំពុងតែបីដើមស្រូវ ឬក៏បីសន្ទូង ហើយដៃម្ខាងទៀត ដែលជាដៃឆ្វេង គាត់ក៏ចាប់ដើមស្រូវ
ដោតចូលទៅក្នុងស្រែរបស់គាត់ម្តងមួយដើមៗ ជាជួរៗ អញ្ចឹងជាទូទៅការស្ទូងស្រូវ
គឺគេស្ទូងមួយដើមៗ ហើយស្ទូងជាជួរៗរបស់វាឲ្យមានសណ្តាប់ធ្នាប់
អញ្ចឹងយើងឃើញសន្ទូងគឺមានសណ្តាប់ធ្នាប់ជាងសំណាប
ដោយសារតែសំណាបគឺកើតឡើងចេញពីការបាចគ្រាប់ស្រូវចូលទៅក្នុងស្រែ អញ្ចឹងវាដុះរាយប៉ាយ
ឬក៏រប៉ាត់រប៉ាយ ប៉ុន្តែសន្ទូង គឺយើងយកដើមស្រូវខ្ចី ឬក៏សំណាប
យកមកដោតចូលទៅក្នុងស្រែម្តងទៀត ដោយដោតជាជួរៗម្តងមួយដើមៗ
ដូច្នេះយើងឃើញសន្ទូងគឺមានសណ្តាប់ធ្នាប់ជាងសំណាប។

បន្ទាប់មកទៀតចូលដល់រូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញសន្ទូងកំពុងតែបែកគុម្ព
អញ្ចឹងក្រោយពីពេលស្ទូងបានរយៈពេលប្រហែលជាមួយខែ អញ្ចឹងប្រហែលជាមួយខែក្រោយមក
គឺសន្ទូងចាប់ផ្តើមបែកគុម្ព ដោយយើងឃើញនៅក្នុងរូបភាពទី ៧ នេះ គឺដើមស្រូវខ្ចីៗនោះ
គឺមានសភាពធំជាងមុន បានន័យថាកាលពេលស្ទូងគឺយើងស្ទូងតែមួយដើមៗ អញ្ចឹងវាតូច
ក៏ប៉ុន្តែក្រោយពេលមួយខែក្រោយមក គឺដើមស្រូវចាប់ផ្តើមរីកធំទៅៗ បានន័យថាវាកំពុងតែបែកគុម្ព
បានន័យថាដើមស្រូវមួយដើមនោះវាដុះចេញច្រើនដើម អញ្ចឹងធ្វើឲ្យគុម្ពរបស់វាធំៗជាងមុន
អញ្ចឹងនៅក្នុងរូបភាពទី ៧ នេះ គឺដើមស្រូវ ឬក៏សន្ទូង កំពុងតែបែកគុម្ព ដោយយើងឃើញ
គេដាំវានៅក្នុងទឹកដដែល អញ្ចឹងសន្ទូងគឺត្រូវការទឹកច្រើន
ដូច្នេះយើងអត់ត្រូវឲ្យរីងទឹកពីក្នុងស្រែនោះទេ ប្រសិនបើរីងទឹក អញ្ចឹងសន្ទូងអាចនឹងងាប់
អញ្ចឹងគេអត់ឲ្យរីងទឹកទេ គឺគេត្រូវការឲ្យមានទឹកនៅក្នុងស្រែជារៀងរហូត គឺនៅពេលណាដែលរីងទឹក
គឺកសិករនឹងបូមទឹកបញ្ចូលស្រែម្តងទៀត ដើម្បីឲ្យទឹក ដើម្បីឲ្យប្រាកដថា
មានទឹកនៅក្នុងស្រែរបស់គេគ្រប់គ្រាន់ ដើម្បីធ្វើឲ្យសន្ទូងរបស់គេលូតលាស់ អញ្ចឹងនៅក្នុងរូបភាពទី
៧ គឺយើងឃើញសន្ទូងកំពុងតែបែកគុម្ពនៅក្នុងស្រែ។

បន្ទាប់មករូបភាពទី ៨ នៅក្នុងរូបភាពទី ៨ គឺយើងឃើញកសិករកំពុងតែច្រូតស្រូវ អញ្ចឹងស្រូវ
ឬក៏ដើមស្រូវដែលទុំ គឺមានពណ៌ក្រហម អញ្ចឹងអម្បាញ់មិញ នៅក្នុងរូបភាពទី ៧
យើងឃើញសន្ទូងពណ៌បៃតងកំពុងតែបែកគុម្ព រហូតមកដល់រូបភាពទី ៨ គឺស្រូវផ្លែ ហើយទុំ
អញ្ចឹងនៅពេលដែលស្រូវទុំ គឺមានពណ៌មាស ឬក៏ពណ៌លឿង អញ្ចឹងដើមស្រូវក៏មានពណ៌មាស
ឬក៏ពណ៌លឿងដូចគ្នា នៅពេលដែលស្រូវទុំ អញ្ចឹងហើយ នៅពេលដែលស្រូវទុំ គឺកសិករ
គាត់កំពុងតែច្រូតស្រូវ អញ្ចឹងការប្រមូលផលស្រូវ គឺយើងហៅថាការច្រូតស្រូវ
ដោយនៅក្នុងរូបភាពនេះ គឺយើងឃើញកសិករ គាត់កំពុងតែដើរនៅក្នុងស្រូវរបស់គាត់
ដើរនៅក្នុងដើមស្រូវរបស់គាត់ដើម្បីច្រូត ដោយយើងឃើញដៃឆ្វេងគាត់កាន់ដើមស្រូវពណ៌លឿង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

រឹងដៃស្ដាំគាត់កាន់ឧបករណ៍សម្រាប់ច្រូតស្រូវ អញ្ចឹងឧបករណ៍សម្រាប់ច្រូតស្រូវ យើងហៅថាកណ្ដៀវ អញ្ចឹងគេអត់ប្រើកាំបិត ឬក៏ពូថៅ ដើម្បីទៅកាត់ដើមស្រូវនោះទេ គឺគេមានឧបករណ៍សម្រាប់កាត់ដើមស្រូវ យើងហៅថាកណ្ដៀវ ដែលវាមានមុខ មានធ្មេញតូចៗដូចរណារដែរ តែវាមានរាងកោង ហើយវាមានដងឈើសម្រាប់ចាប់កាន់ អញ្ចឹងវាជាធ្វើអំពីដែក ដោយមានដងឈើសម្រាប់ចាប់កាន់ ហើយវាមានធ្មេញតូចៗ ដូចរណារ ក៏ប៉ុន្តែវាមានរាងកោងខាងមុខបន្តិច ដើម្បីងាយស្រួលក្នុងការច្រូតស្រូវ អញ្ចឹងការប្រមូលផលស្រូវទុំ យើងហៅថាការច្រូតស្រូវ ហើយឧបករណ៍សម្រាប់ច្រូតស្រូវ គឺយើងហៅថាកណ្ដៀវ នៅក្នុងរូបភាពទី ៨ គឺកសិករ គាត់កំពុងតែប្រមូលផលស្រូវ ឬក៏គាត់កំពុងតែច្រូតស្រូវ។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ បន្ទាប់ពីគាត់ច្រូតស្រូវរួចរាល់ហើយ អញ្ចឹងបន្ទាប់ពីកសិករ គាត់ច្រូតស្រូវរួចរាល់ហើយ យើងឃើញកសិករ គាត់កំពុងតែយកដើមស្រូវ ដែលមានស្រូវទុំ ឬមានផ្លែស្រូវទុំនៅជាប់ដើមនោះ មកបោកទៅនឹងក្ដារ ឬក៏ទៅនឹងថ្មមួយ អញ្ចឹងការធ្វើបែបនេះ យើងហៅថាការបោកស្រូវ ឬក៏ការបែនស្រូវ អញ្ចឹងដើម្បីប្រឡេះយកគ្រាប់ស្រូវចេញពីដើម គឺយើងអត់ប្រើដៃយើងប្រឡេះគ្រាប់ស្រូវម្ដងមួយគ្រាប់ៗនោះទេ គឺវាប្រើពេលយូរ ដោយសារតែដើមស្រូវនីមួយៗគឺមានផ្លែច្រើន ហើយក្នុងស្រែនីមួយៗគឺមានដើមស្រូវច្រើនផងដែរ ដូច្នេះ ដើម្បីឲ្យចំណេញពេលវេលា គឺយើងយកដើមស្រូវទាំងនោះទៅបោកទៅនឹងថ្ម ឬក៏បោកទៅនឹងក្ដារមួយបន្ទះ ដើម្បីឲ្យគ្រាប់ស្រូវជ្រុះមកក្រោម អញ្ចឹងដើម្បីប្រមូលផលស្រូវឲ្យបានល្អ គឺគេអត់បោកទៅផ្ទាល់នឹងដីនោះទេ គឺគេមានក្រាលកន្ទេលមួយ ដែលប្រជាជនកម្ពុជាតែងតែប្រើកន្ទេលដែលធ្វើអំពីស្លឹកត្នោត អញ្ចឹងគឺយើងបោកស្រូវនៅលើកន្ទេលស្លឹកត្នោត ហើយនៅពេលដែលគ្រាប់ស្រូវជ្រុះមក គឺជ្រុះនៅលើកន្ទេល ដូច្នេះកសិករងាយស្រួលប្រមូល ដោយមិនឲ្យគ្រាប់ស្រូវទាំងនោះប្រឡាក់ជាមួយនឹងដី អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញកសិករ គាត់ពាក់អាវដៃវែង ខោជើងវែងដដែល ព្រោះថាដើមស្រូវគឺធ្វើឲ្យយើង អាចធ្វើឲ្យយើងរមាស់បាន ប្រសិនបើយើងអត់ពាក់អាវដៃវែង ឬក៏អត់ពាក់ខោជើងវែងទេ នៅពេលដែលយើងប៉ះពាល់ជាមួយដើមស្រូវ គឺដើមស្រូវអាចធ្វើឲ្យយើងរមាស់ខ្លួនបាន ដូច្នេះដើម្បីកុំឲ្យរមាស់គឺយើងត្រូវការពារខ្លួនយើងដោយពាក់អាវដៃវែង ឬក៏ខោជើងវែងជាដើម អញ្ចឹងនៅក្នុងរូបភាពនេះគឺគាត់កំពុងតែកាន់ដើមស្រូវមួយគុម្ព ហើយបោកទៅនឹងថ្មមួយ អញ្ចឹងនៅពេលដែលបោក គឺយើងឃើញគាត់បោកម្ដងមួយគុម្ពៗ ហើយយើងឃើញគ្រាប់ស្រូវកំពុងតែជ្រុះចេញពីដើមស្រូវទាំងនោះ អញ្ចឹងយើងឃើញនៅខាងមុខថ្ម គឺមានគ្រាប់ស្រូវពណ៌លឿងជាច្រើន ដែលជ្រុះនៅខាងមុខថ្ម អញ្ចឹងយើងឃើញថា

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់បោកស្រូវដើម្បីយកស្រូវចេញពីដើមស្រូវ ដោយនៅខាងក្រោយគាត់ យើងឃើញ
មានដើមស្រូវជាច្រើនទៀត ដែលមិនទាន់បោករួចរាល់ ដូច្នេះកសិករគាត់ត្រូវតែបោកស្រូវ
ដើម្បីប្រមូលផលស្រូវចេញពីដើមស្រូវ
អញ្ចឹងនៅពេលដែលយើងប្រមូលផលស្រូវចេញពីដើមស្រូវរួចរាល់ហើយ
ដើមស្រូវដែលអត់មានគ្រាប់ស្រូវ យើងហៅថាចំបើង អញ្ចឹងដើមស្រូវគឺមានប្រយោជន៍ផងដែរ
នៅពេលដែលយើងប្រមូលផល ឬក៏ប្រមូលស្រូវ បោកស្រូវចេញពីដើមអស់ហើយ
គឺយើងអាចយកដើមស្រូវទាំងនោះ យកទៅឲ្យសត្វគោ ឬក៏សត្វក្របីស៊ី អញ្ចឹងសត្វគោ ឬសត្វក្របី
វាស៊ីដើមស្រូវ ឬក៏ចំបើង ជាអាហារ ដូច្នេះកសិករគាត់អត់យកចំបើង
ឬក៏ដើមស្រូវដែលអស់គ្រាប់នោះ យកទៅបោះចោលនោះទេ គឺគាត់អាចយកទៅឲ្យគោ
ឬក្របីរបស់គាត់ស៊ីជាអាហារផងដែរ ដូច្នេះនៅក្នុងរូបភាពទី ៩ គឺកសិករ
គាត់កំពុងតែបោកស្រូវរបស់គាត់ទៅនឹងថ្ម ឬក៏បោកស្រូវរបស់គាត់ទៅនឹងក្តារមួយបន្ទះ
ដើម្បីប្រមូលគ្រាប់ស្រូវចេញពីដើមស្រូវ ហើយយកគ្រាប់ស្រូវនោះទៅប្រើប្រាស់។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញ បន្ទាប់ពីកសិករ
គាត់ប្រមូលផលស្រូវ ឬក៏គាត់ប្រឡេះគ្រាប់ស្រូវ បោកស្រូវចេញពីដើមស្រូវរួចរាល់ហើយ
គាត់យកគ្រាប់ស្រូវនោះមកហាល អញ្ចឹងជាទូទៅគឺគ្រាប់ស្រូវ នៅពេលដែលយើងប្រមូលផលរួច
គឺមានលក្ខណៈសើមៗបន្តិច អញ្ចឹងដើម្បីឲ្យវាស្ងួតល្អ ដើម្បីឲ្យគ្រាប់ស្រូវនោះស្ងួតល្អ
គឺយើងត្រូវយកវាមកហាលក្រោមពន្លឺព្រះអាទិត្យ ដែលរូបភាពទី ១០ នេះ
យើងឃើញមានផ្ទះមួយខ្នងពណ៌ប្រផេះ ហើយផ្ទះនោះគឺជាផ្ទះរបៀបដែល[អ្នក]នៅស្រុកស្រែ
គឺគាត់ធ្វើផ្ទះខ្ពស់ផុតពីដី ដែលមានជើងសសរផងដែរ អញ្ចឹងនៅក្នុងផ្ទះនេះ
យើងឃើញមានជើងសសរបួន ហើយមានកាំជណ្ដើរមួយដើម្បីឡើងទៅលើផ្ទះ
អញ្ចឹងនៅខាងមុខផ្ទះគឺមានរានហាល ដោយឡើងពីកាំជណ្ដើរទៅ យើងឡើងទៅដល់រានហាល
បន្ទាប់មកគឺយើងឃើញផ្ទះមានបង្អួច និងមានដំបូលមួយផងដែរ
អញ្ចឹងផ្ទះនេះគឺជាផ្ទះរបៀបស្រុកស្រែ ដែលគេធ្វើខ្ពស់ផុតពីដី
ដែលនៅក្បែរផ្ទះនោះគឺយើងឃើញមានពាងមួយ ពាងសម្រាប់ដាក់ទឹក
អញ្ចឹងជាទូទៅនៅស្រុកស្រែចំការ គឺអត់មានទឹកម៉ាស៊ីននោះទេ ដូច្នេះហើយគឺកសិករ
គាត់ប្រើប្រាស់ពាង ដើម្បីត្រងទឹកភ្លៀង អញ្ចឹងនៅពេលដែលមានភ្លៀងមក
គឺកសិករត្រងទឹកភ្លៀងដាក់ចូលក្នុងពាងដើម្បីទុកប្រើប្រាស់
ហើយយើងឃើញនៅខាងក្រោយផ្ទះគឺមានភ្នំមួយ អញ្ចឹងភ្នំមួយនោះ គឺនៅជិតផ្ទះរបស់គាត់
ហើយមានដើមឈើជាច្រើនផងដែរ ដែលយើងឃើញដើមខ្លះ គឺជាដើមត្នោត
ហើយដើមឈើផ្សេងៗទៀតជាច្រើនដែលដុះនៅក្បែរៗផ្ទះរបស់គាត់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយយើងឃើញនៅខាងមុខផ្ទះគឺមានកន្ទេលមួយ ឬក៏តង់កៅស៊ូមួយពណ៌ខៀវ
ហើយនៅលើតង់កៅស៊ូ ឬក៏នៅលើកន្ទេលពណ៌ខៀវនោះ គឺមានគ្រាប់ស្រូវពណ៌មាសជាច្រើន
អញ្ចឹងគ្រាប់ស្រូវទុំគឺមានពណ៌មាស ឬក៏ពណ៌លឿង ហើយមានក្លិនក្រអូបផងដែរ គឺ
អាចនៅពេលដែលយើងដើរក្បែរស្រូវទុំ គឺយើងមានក្រអូប ឬក៏ប្រហើរស្រូវទុំផងដែរ
ការហាលស្រូវគឺយើងហាលនៅក្រោមពន្លឺព្រះអាទិត្យ អញ្ចឹងយើងឃើញព្រះអាទិត្យកំពុងតែរះ
និងបញ្ចេញពន្លឺ និងបញ្ចេញកម្ដៅមកលើគ្រាប់ស្រូវដើម្បីឲ្យស្ងួត
ដូច្នេះគ្រាប់ស្រូវដែលយើងទើបតែប្រមូលផលបានភ្លាមៗ គឺមានសភាពសើមៗ
ដូច្នេះហើយគឺយើងអត់អាចយកមកប្រើប្រាស់បានទេ
អញ្ចឹងយើងត្រូវធ្វើយ៉ាងណាឲ្យគ្រាប់ស្រូវស្ងួតជាមុនសិន មុននឹងយើងយកមកបោកឬក៏យកមកកិន
ដើម្បីចេញជាអង្ករ អញ្ចឹងនៅក្នុងរូបភាពទី ១០ គឺយើងឃើញកសិករ
គាត់កំពុងតែហាលស្រូវរបស់គាត់នៅក្រោមពន្លឺព្រះអាទិត្យ ដើម្បីឲ្យស្រូវរបស់គាត់ស្ងួត។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញមានត្បាល់មួយ
អញ្ចឹងត្បាល់សម្រាប់បុកស្រូវ ដោយត្បាល់នោះគឺយើងឃើញជាត្បាល់ជាន់ ដោយយើងធ្វើអំពីឈើ
ដោយត្បាល់នោះគឺមានសសរពីរដើម សសរពីរដើមនោះចោះដោយដែកមួយ
ហើយមានសសរមួយទៀតនៅកណ្ដាល ដែលមានរាងវែងបន្តិចផ្ដេកទៅមុខ អញ្ចឹងសសរទាំងពីរ
ទាំងបីនោះ ភ្ជាប់គ្នាដោយដែកមូលមួយនៅកណ្ដាល
ហើយនៅពេលដែលយើងឃើញសសរផ្ដេកនោះ គឺមានចុងម្ខាង គឺមានបណ្ដូល ដូច្នេះគឺ
បណ្ដូលនោះ គឺជា យើងហៅថាអង្រែសម្រាប់បុកស្រូវ អញ្ចឹងត្បាល់នេះគឺជាប្រភេទត្បាល់ជាន់
ហើយយើងជាន់នៅចុងម្ខាង ដើម្បីឲ្យចុងម្ខាងទៀតបះ ហើយនៅក្រោមត្បាល់ផ្ដេក ឬក៏ឈើផ្ដេកនោះ
គឺយើងឃើញមានត្បាល់មួយ ដែលមានរាងប្រហោងកណ្ដាល
ដូច្នេះយើងដាក់ស្រូវចូលទៅក្នុងប្រហោងកណ្ដាលនោះ ហើយយើងជាន់អង្រែ
ដើម្បីបុកស្រូវឲ្យចេញជាអង្ករ នេះគឺជាវិធីបុរាណសម្រាប់ធ្វើការបកគ្រាប់ស្រូវ ដើម្បីយកអង្ករ
គឺយើងហៅថាបុកស្រូវដើម្បីយកអង្ករ អញ្ចឹងវិធីបុរាណនេះគឺវាពិបាកនៅក្នុងការប្រើប្រាស់បន្តិច
ដោយសារតែយើងត្រូវប្រើប្រាស់កម្លាំងច្រើន ដើម្បីបកគ្រាប់ស្រូវ ដើម្បីយកអង្ករពណ៌ស
អញ្ចឹងដើម្បីមុននឹងបានអង្ករ គឺយើងត្រូវបុកស្រូវជាមុនសិន ដើម្បីឲ្យគ្រាប់ស្រូវទាំងនោះបែក
ហើយចេញជាអង្ករមក ប៉ុន្តែបច្ចុប្បន្ននេះគឺគេប្រើម៉ាស៊ីន ដូចជាយើងឃើញនៅក្នុងរូបភាពទី ១១
ដដែល ដែលនៅខាងស្ដាំដៃ គឺជាម៉ាស៊ីនកិនស្រូវ អញ្ចឹងនៅសម័យបច្ចុប្បន្ន គេលែងប្រើត្បាល់ជាន់
ឬក៏ត្បាល់បុកស្រូវទៀតហើយ ដោយសារតែវាយូរនិងពិបាក ហើយប្រើប្រាស់កម្លាំងច្រើន
ដូច្នេះគេប្រើម៉ាស៊ីនដើម្បីកិនស្រូវតែម្ដង អញ្ចឹងយើងគ្រាន់តែចាក់គ្រាប់ស្រូវរបស់យើង
ដែលហាលរួច ដែលហាលស្ងួតរួច ចូលទៅក្នុងម៉ាស៊ីន នោះម៉ាស៊ីននឹងចាប់ផ្ដើមកិន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយបំបែកគ្រាប់ស្រូវដោយបកគ្រាប់ស្រូវចេញជាអង្ករភ្លាមៗ
អញ្ចឹងអង្ករគឺព័ទ្ធដោយគ្រាប់ស្រូវសំបកស្រូវ អញ្ចឹងនៅពេលដែលយើងបកសំបកស្រូវនោះចេញ
នឹងមានអង្ករពណ៌សនៅក្នុងនោះ អញ្ចឹងនៅពេលដែលយើងចាក់គ្រាប់ស្រូវដែលស្ងួត
ចូលទៅក្នុងម៉ាស៊ីន ម៉ាស៊ីននឹងធ្វើការបកគ្រាប់ស្រូវនោះឲ្យចេញជាអង្ករពណ៌សតែម្តង
គឺវាចំណេញពេល និងមិនសូវពិបាកដល់កម្លាំងមនុស្សផងដែរ ហើយសំបកស្រូវ
ដែលបកចេញជាអង្ករហើយ វានឹងក្លាយទៅជាកន្ទក់
ដូច្នេះកន្ទក់គឺយើងអាចយកទៅចិញ្ចឹមសត្វផងដែរ ដូចជាសត្វជ្រូកគឺវាស៊ីកន្ទក់
ដែលជាសំបកស្រូវនោះឯង ហើយអង្ករគឺមនុស្សយកមកបរិភោគ ដូច្នេះនៅក្នុងរូបភាពទី ១១
គឺបង្ហាញអំពីការបកគ្រាប់ស្រូវពីវិធីបុរាណនិងវិធីសម័យ ដោយវិធីបុរាណ គេបកគ្រាប់ស្រូវ
ដោយប្រើប្រាស់ត្បាល់បុកស្រូវ ឬក៏ត្បាល់ជាន់ រីឯសម័យ ឬក៏ពេលបច្ចុប្បន្ន
គឺយើងប្រើប្រាស់ម៉ាស៊ីនកិនស្រូវ ដូច្នេះការបកគ្រាប់ស្រូវគឺមានវិធីពីរ គឺប្រើប្រាស់វិធីបុរាណ
និងប្រើប្រាស់វិធីសម័យ ឬក៏បច្ចុប្បន្ន ដោយប្រើប្រាស់ម៉ាស៊ីនកិនស្រូវ។

បន្ទាប់មករូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញ បន្ទាប់ពីគេកិនស្រូវហើយ
ស្រូវនោះនឹងក្លាយទៅជាអង្ករ អញ្ចឹងអង្ករគឺមានពណ៌សដែលខុសពីស្រូវ ដោយស្រូវគឺមានពណ៌មាស
ដោយសារតែសំបករបស់អង្ករគឺមានពណ៌លឿង
ដូច្នេះនៅពេលដែលអង្ករមិនទាន់បានបកសំបកចេញគេហៅថាស្រូវ
នៅពេលដែលគេបកសំបកចេញរួចហើយ គឺគេហៅថាអង្ករ អញ្ចឹងអង្ករគឺមានពណ៌ស
ដូច្នេះនៅក្នុងរូបភាពទី ១២ គឺយើងឃើញគេកំពុងតែយកចានមួយចូកអង្ករចេញពីក្នុងបាវ
អញ្ចឹងចានមួយ គឺយើងឃើញមានដៃមួយកំពុងតែកាន់ចានពណ៌ខៀវ
ហើយចូកអង្ករពណ៌សចេញពីក្នុងបាវពណ៌លឿងមួយ អញ្ចឹងគេចូកអង្ករ
ដើម្បីយកទៅប្រើប្រាស់ដូចជាដាំបាយ ឬក៏ដាំបបរផ្សេងៗ អញ្ចឹងរូបភាពនេះ
គឺគេកំពុងតែវាល់អង្ករចេញពីក្នុងបាវដើម្បីយកទៅដាំបាយ។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ គឺយើងឃើញ
បន្ទាប់ពីគេវាល់អង្ករចេញពីក្នុងបាវហើយ គេក៏ចាក់អង្ករនោះចូលទៅក្នុងឆ្នាំងមួយ អញ្ចឹងដើម្បីឲ្យ
ច្បាស់លាស់នៅក្នុងការដាំបាយ គឺយើងប្រើកំប៉ុង ឬក៏ប្រើចានដើម្បីវាល់ អញ្ចឹងវាជារង្វាស់រង្វាល់
ដើម្បីវាស់ថាតើយើងត្រូវការអង្ករប៉ុន្មានដើម្បីញ៉ាំគ្រប់គ្នា ដូច្នេះគឺយើងប្រើកំប៉ុងឬក៏ចាន
ដើម្បីវាល់អង្ករ អញ្ចឹងនៅក្នុងរូបភាពទី ១៣ គឺយើងឃើញ
បន្ទាប់ពីគេយកចានដួសអង្ករចេញពីក្នុងបាវហើយ គេយកអង្ករនោះទៅចាក់ចូលទៅក្នុងឆ្នាំង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយនៅក្នុងឆ្នាំងនោះ យើងហៅថាឆ្នាំងដាំបាយ អញ្ចឹងនៅក្នុងរូបភាពនេះ
គឺយើងយកអង្ករចាក់ចូលទៅក្នុងឆ្នាំងដើម្បីដាំបាយ។

បន្ទាប់មកទៀតរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញ
បន្ទាប់ពីយើងវាល់អង្ករចាក់ចូលទៅក្នុងឆ្នាំងរួចរាល់ហើយ គឺគេចាក់ទឹកចូលទៅក្នុងឆ្នាំងផងដែរ
អញ្ចឹងដើម្បីដាំបាយ ឬក៏ដាំបបរ គឺយើងត្រូវការអង្ករ និងត្រូវការទឹក
អញ្ចឹងបន្ទាប់ពីគេដាក់អង្ករចូលក្នុងឆ្នាំ គេត្រូវចាក់ទឹកល្មមចូលទៅក្នុងឆ្នាំងបាយនោះផងដែរ ដើម្បីដាំ
អញ្ចឹងនៅក្នុងរូបភាពទី ១៤ នេះ គឺយើងឃើញ យើងឃើញគេកំពុងតែចាក់ទឹកចូលទៅក្នុងឆ្នាំង
ក្នុងកម្រិតបរិមាណមួយល្មមដើម្បីដាំបាយ បន្ទាប់មកទៀតគឺគេយកគម្របឆ្នាំងដើម្បីគ្រប
ហើយគេយកឆ្នាំងនោះទៅដាក់នៅលើភ្លើង ឬក៏ដាក់នៅលើចង្ក្រាន អញ្ចឹងដើម្បីដាំបាយ
គឺគេត្រូវការប្រើប្រាស់ភ្លើងចង្ក្រាន ដើម្បីដាំឲ្យក្តៅផងដែរ
អញ្ចឹងនៅពេលដែលយើងដាក់ទឹកលាយជាមួយអង្ករទៅក្នុងឆ្នាំង
ហើយយកទៅដាក់នៅលើចង្ក្រានដែលមានភ្លើង នោះទឹកនឹងចាប់ផ្តើមពុះ
នៅពេលដែលទឹកចាប់ផ្តើមពុះ អង្ករដែលនៅក្នុងឆ្នាំងនឹងចាប់ផ្តើមរីក
អញ្ចឹងយើងឃើញមានផ្សែងហុយចេញពីគម្របឆ្នាំងផងដែរ អញ្ចឹងនៅពេលដែលផ្សែងហុយ
គឺមានន័យថាទឹកពុះ ឬក៏បាយពុះ អញ្ចឹងយើងត្រូវមើលថាតើអង្ករនោះរីកហើយឬនៅ
នៅពេលដែលអង្កររីក គឺបានន័យថាវាក្លាយទៅជាបាយ អញ្ចឹងមុនពេលដែលដាំគឺយើងហៅថាអង្ករ
នៅពេលដែលយើងយកទៅដាំជាមួយនឹងទឹក ហើយវារីកហើយ គឺយើងហៅថាបាយ
ដូច្នេះនៅក្នុងរូបភាពទី ១៤ គឺគេកំពុងតែដាំបាយ ដោយយើងឃើញមានឆ្នាំងបាយកំពុងតែពុះ
ហុយផ្សែងចេញទៅលើ បានន័យថាឆ្នាំងនោះកំពុងតែក្តៅ ហើយបាយកំពុងតែពុះ។

បន្ទាប់មកទៀតចូលដល់រូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ គឺយើងឃើញ
គេកំពុងតែដួសបាយចេញពីក្នុងឆ្នាំង អញ្ចឹងនៅក្នុងរូបភាពទី ១៥ នេះ គឺយើងឃើញ
គេបើកគម្របឆ្នាំងបាយ ដែលមានផ្សែងហុយៗចេញពីក្នុងឆ្នាំងបាយ ហើយមានដៃពីរ
ដែលកំពុងតែដួសបាយចេញពីក្នុងឆ្នាំងដោយប្រើវែកពណ៌លឿងមួយ
អញ្ចឹងគេដួសបាយដាក់ចូលទៅក្នុងចាន តាមកម្រិតមួយល្មមដែលគេអាចហូបអស់
អញ្ចឹងគេដួសបាយដោយប្រើវែក ឧបករណ៍សម្រាប់ដួសបាយចេញពីក្នុងឆ្នាំង យើងហៅថាវែក
អញ្ចឹងគេ យើងឃើញគេកំពុងតែដួសបាយចេញពីក្នុងឆ្នាំងម្តងមួយវែកៗដាក់ចូលទៅក្នុងចាន
ដោយយើងឃើញនៅក្បែរនោះគឺមានចានគោមពីរ គឺពណ៌ទឹកក្រូច អញ្ចឹងចានមួយគឺមានបាយពេញ
ឯចានមួយទៀតគឺគេកំពុងតែដួសបាយចេញពីក្នុងឆ្នាំងដាក់ចូលទៅក្នុងចាន អញ្ចឹងរូបភាពទី ១៥
គឺគេកំពុងតែដួសបាយដាក់ចូលទៅក្នុងចាន។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៦ រូបភាពទី ១៦ គឺយើងនិយាយអំពីឧបករណ៍សម្រាប់ដាក់បាយ
អញ្ចឹងឧបករណ៍សម្រាប់ដាក់បាយគឺមានច្រើន អញ្ចឹងឆ្នាំងគឺយើងប្រើសម្រាប់ដាំបាយ
រីឯចានគឺយើងប្រើប្រាស់សម្រាប់ដាក់បាយ អញ្ចឹងនៅពេលដែលយើងញ៉ាំបាយ
គឺយើងអត់ញ៉ាំនៅក្នុងឆ្នាំងនោះទេ គឺយើងញ៉ាំនៅក្នុងចាន ដូច្នេះយើងត្រូវដួសបាយដាក់ក្នុងចាន
ដើម្បីញ៉ាំ រីឯជំនាន់បុរាណ ឬក៏សម័យបុរាណ គឺគេអត់មានចានប្រើប្រាស់នោះទេ បានន័យថាចាន
គឺគេប្រើប្រាស់នៅសម័យបច្ចុប្បន្ន ក៏ប៉ុន្តែនៅក្នុងសម័យបុរាណគឺគេអត់មានចានប្រើប្រាស់ទេ
គឺគេប្រើប្រាស់ស្មុគ អញ្ចឹងស្មុគគឺជាឧបករណ៍សម្រាប់ដាក់បាយមួយ ដែលធ្វើឡើងអំពីស្លឹកត្នោត
អញ្ចឹងដូចដែលយើងឃើញនៅក្នុងរូបភាពទី ១៦ គឺចានមានពណ៌ផ្កាឈូក
ដែលមានបាយនៅក្នុងនោះ ដែលនៅក្បែរចាននោះគឺមានស្មុគមួយពណ៌លឿង
ដែលធ្វើអំពីស្លឹកត្នោត អញ្ចឹងពីបុរាណ គេប្រើប្រាស់ស្មុគ ដែលធ្វើអំពីស្លឹកត្នោត ដើម្បីដួសបាយ
ឬក៏ដាក់បាយដើម្បីហូប អញ្ចឹងស្មុគធ្វើពីស្លឹកត្នោត ហើយមានគម្របស្លឹកត្នោតផងដែរ
ដែលឧបករណ៍ទាំងពីរនេះ គឺយើងអាចប្រើប្រាស់ដាក់បាយបានដូចគ្នា
ចំណែកឯយើងឃើញមាននៅក្បែរនោះ គឺមានពំនូកបាយមួយទៀតរាងពណ៌ក្រមៅបន្តិច
អញ្ចឹងបាយពណ៌ក្រមៅអាចជាបាយដំណើប យើងហៅថាបាយដំណើប
ដូច្នេះបាយវាមានច្រើនប្រភេទ វាមានអង្ករខ្សាយ ឬក៏អង្ករធម្មតា ហើយមួយទៀតគឺអង្ករដំណើប
អញ្ចឹងអង្ករដំណើប ក៏គេប្រើប្រាស់ឬក៏ញ៉ាំផងដែរនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែអង្ករដំណើប
ឬក៏បាយដំណើប គឺយើងប្រើប្រាស់សម្រាប់ធ្វើជាបង្អែម
អញ្ចឹងយើងអត់ញ៉ាំនៅក្នុងពេលប្រចាំថ្ងៃនោះទេ គឺយើងប្រើប្រាស់វាសម្រាប់ធ្វើជាបង្អែម
ដោយយើងមានបង្អែមបាយដំណើបសំខ្យាជាដើម ចំណែកឯអង្ករខ្សាយ ឬអង្ករធម្មតា
គឺយើងដាំបាយញ៉ាំរាល់ថ្ងៃ ជាមួយនឹងម្ហូបផ្សេងៗ ដូច្នេះនៅក្នុងប្រទេសកម្ពុជា គឺយើងធ្វើស្រែ
ដើម្បីយកស្រូវ ដើម្បីយកអង្ករ យកមកដាំបាយហូប ឬក៏ដាំបាយញ៉ាំជាមួយនឹងម្ហូបផ្សេងៗ
អញ្ចឹងនៅខាងអឺរ៉ុប យើងឃើញគាត់អត់សូវញ៉ាំបាយនោះទេ ប៉ុន្តែភាគច្រើនគាត់ញ៉ាំនំប៉ុង
ប៉ុន្តែប្រជាជននៅក្នុងអាស៊ី ភាគច្រើនគឺ ជាពិសេសនៅក្នុងអាស៊ីអាគ្នេយ៍ គឺយើងញ៉ាំបាយជាអាហារ
ជាក់ស្តែងដូចជាប្រទេសកម្ពុជា គឺយើងញ៉ាំបាយជាអាហារប្រចាំថ្ងៃរបស់យើង សម្រាប់អាហារបីពេល
គឺពេលព្រឹក ពេលល្ងាច និងពេលថ្ងៃត្រង់ គឺយើងប្រើប្រាស់បាយអង្ករធម្មតាដើម្បីញ៉ាំ
ក៏ប៉ុន្តែនៅក្នុងប្រទេសជិតខាង ដូចជាប្រទេសឡាវជាដើម គឺគាត់ប្រើប្រាស់អង្ករដំណើប
ដើម្បីញ៉ាំបាយជាប្រចាំថ្ងៃ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.